តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# Business Integrity Country Agenda (BICA) Assessment

# Business Sector Brief

Cambodia has a labour intensive economy dominated by manufacturing, tourism, construction and agriculture industries. In 2004, Cambodia ascended to the World Trade Organisation. Since then, the economy was largely liberalized through a number of legislative initiatives such as The Law on Commercial Enterprises, the Commercial Arbitration Law, the Anti-Corruption Law and the Securities Law. The Royal Government of Cambodia ("RGC") also provides important incentives for investors such as establishment of Special Economic Zones (SEZs) and providing tax exemptions for Qualified Investment Projects (QIPs). As a result, between 2004 and 2015, the annual average growth of FDI and export of goods, have been 38% and 13% respectively (World Bank and COMTRADE statistics).

However, the Cambodian economy remains highly vulnerable due to its low diversification, 78% of merchandise exports is related to garment and footwear products. As a former Least Developed Country, Cambodia has benefited from the duty-free and quota-free access to EU markets under the "Everything but Arms" program. This might change due to the revision of its status by the World Bank to a Lower-Middle Income Country.

These trends have obliged RGC to undertake a set of reforms in order to ensure fair competition, facilitation of trade, efficient public administration and better infrastructure. For instance, the Ministry of Commerce ("MoC) is undertaking considerable efforts to register most of the business establishments by providing online business registration services. Since 2009, the General Department of Taxation has increased the annual tax collection by 19% on average.

These reforms are challenging due to the fact that the Cambodian economy is dominated by micro enterprises (having less than 10 employees) which in 2014 accounted for 97.2% of all establishments and only 1.2% of them were registered at MoC (Cambodian 2014 Inter-Censal Economic Survey). In addition, an important part of the economy is informal and many workers are self-employed or working without a contract, and work from their homes, small shops, or on the street. It is clear that there remains a substantial gap between the stated market objectives in Cambodia and the realities of doing business.

Thus, it is obvious that with the ongoing globalization and integration within ASEAN Economic Community, Cambodian companies must improve their corporate governance and to implement a set of business integrity practices in order to efficiently cooperate and compete with foreign companies, to be compliant in order to attract investments and to be trustworthy in the eyes of their shareholders.

The BICA research has found that mostly multinational and joint ventures establish clear strategies against corruption, but very few domestic companies have integrity management policies in place. Cambodian companies are largely not in the habit of disclosing their anticorruption programs, operations, or organisational layouts, in large part because this information is not legally required. Generally, domestic companies and especially SMEs lack a corporate culture and do not see the benefits of adopting odes of conduct, internal and external whistleblowing channels for cases of corruption and public disclosure of corporate information. It should

The BICA Assessment Report is a baseline assessment of public, private and civil society sector efforts to promote business integrity, particularly accountability, transparency, and integrity in business practices. This report seeks to further understand the factors and actions that can increase business integrity in Cambodia, in order to facilitate public, private, and civil society efforts to diminish corruption.

be highlighted that for small domestic companies adopting such practices might be costly. Only listed enterprises on the CSX have such legal obligations. Moreover, only companies with a turnover of more than 750,000 USD, 500,000 USD assets and 100 employees must submit annual financial statements to an independent auditor certified by the KICPAA.

The main avenue for private sector companies to engage in multi-stakeholder initiatives on anti-corruption is through the business associations and Chambers. These entities provide many services (legal advice, networking, up-to date information, etc.) to their members and also have established good cooperation with key government ministries, as well as with the Anti-Corruption Unit (ACU). However, it has been reported that private companies are missing effective channels of communication with public institutions.

Larger multinational companies have officially engaged with the ACU by signing Memorandums of Understanding ("MoUs"). The content of these MoUs is not publically available and the outcomes and benefits in engaging with the ACU for individual companies, especially SMEs are not clear. Companies largely are not transparent in disclosing information about their anti-corruption programmes or their corporate information. Based on the BICA research, there was a clear disconnect between the information that was available on a foreign company's website and a domestic company's websites. Domestic companies tend not to disclose any anti-corruption policies and corporate information due to the lack of legal obligations and low corporate governance culture.

Overall, many companies indicate a willingness to adopt anti-corruption programmes and become legally compliant with current legislation. More cooperation with stakeholders and training is necessary to further develop corporate governance especially within domestic companies. There is a need for more legislative initiatives regarding the promotion of corporate governance and adoption of anti-corruption policies. Additional whistleblowing channels should be introduced and more information should be disclosed on the companies' websites. It is important to reduce the size of the informal sector by providing incentives for enterprises to register at the MoC and GDT and for business associations to strongly encourage and facilitate registration. These measures would eventually further improve the business environment in Cambodia and the competitiveness of domestic enterprises.

## Key recommendations for the business sector include:

- The chambers of commerce and business associations should disclose information about the benefits of engaging closely with the ACU to their members, particularly, the importance of protection for potential whistleblowers who report to the ACU.
- Business associations and chambers of commerce should continue to organize training in business integrity and corporate practices (i.e. codes of conduct, codes of ethics, anti-corruption reporting channels, anti-corruption policies), including working closely with the ACU to establish and train in best practices.
- Business associations should identify benchmarks for business integrity in each industry and acknowledge and reward companies who achieve them.
- Domestic and international companies should establish anonymous, and protected lines for whistleblowing to encourage employees at all levels to report cases of corruption or other wrongdoing.
- Companies should ensure compliance by registering with the MoC and the GDT. Business associations should encourage the process and assist whenever possible.

  Companies should disclose anti-corruption policies and activities in their annual reports and on their websites.
- Business associations should encourage companies to understand the value of clean accounting practices and the value added by professional accounting services.
- Companies should require anti-corruption due diligence of their partners and suppliers and create a database of clean companies.
- Private companies should offer more channels to report cases of corruption. Reporting exclusively to ACU is insufficient.
- Chambers of commerce should promote and advise ministries on drafting and promulgating relevant legislation, including the draft law on the protection of reporting persons, the draft law on the protection of experts, victims and witnesses and the draft law on competition and update existing laws which are outdated or run counter to anti-corruption objectives. This should be in consultation with the private sector and civil society.

***Transparency International Cambodia***
*#3, Street 390, Sangkat BoengKengkang 3,*
*Khan Chamkarmorn,*
*Phnom Penh, Kingdom of Cambodia*

( +855 ) 23 214 430

*Website: www.ticambodia.org*
*Global website: www.transparency.org*

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ

## សេចក្តីសង្ខេបស្តីពីវិស័យធុរកិច្ច

សេដ្ឋកិច្ចប្រទេសកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើកម្លាំងពលកម្ម ក្នុងនោះមានវិស័យផលិតកម្ម ទេសចរណ៍ សំណង់ និង កសិកម្ម។ នៅឆ្នាំ២០០៤ ប្រទេសកម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ចាប់ពីពេលនោះមកប្រទេសកម្ពុជាបានធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច តាមរយៈគំនិតផ្តួចផ្តើមលើនីតិប្បញ្ញត្តិមួយចំនួន ដូចជា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីមជ្ឈត្តការផ្អែកពាណិជ្ជកម្ម ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់មូលបត្រ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តល់ការលើកទឹកចិត្តពិសេសៗដល់វិនិយោគិន ដូចជា ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) និងការលើកលែងពន្ធសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ។ ជាលទ្ធផល ចន្លោះពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៥ កំណើនជាមធ្យមប្រចាំឆ្នាំពីការវិនិយោគផ្ទាល់ពីបរទេសមានប្រមាណ ៣៨% និងការនាំចេញទំនិញមាន ១៣% (ស្ថិតិរបស់ធនាគារពិភពលោក និង COMTRADE) ។

យ៉ាងណាមិញ សេដ្ឋកិច្ចរបស់កម្ពុជានៅតែមានភាពងាយរងគ្រោះខ្ពស់ ដោយសារតែការធ្វើពិពិធកម្មមានទំហំតូចនៅឡើយ ដែលក្នុងនោះ ៧៨% នៃទំនិញនាំចេញ គឺជាផលិតផលទាក់ទងនឹងសម្លៀកបំពាក់ និងស្បែកជើង។ ក្នុងនាមជាអតីតប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាបានទទួលផលប្រយោជន៍ពីលទ្ធភាពទទួលបានការអនុគ្រោះពន្ធ និងមិនមានកូតាទៅកាន់ទីផ្សារសហភាពអឺរ៉ុប ក្រោមកម្មវិធី "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ"។ ប្រការនេះ អាចត្រូវបានផ្លាស់ប្តូរ ដោយសារធនាគារពិភពលោកបានកែប្រែស្ថានភាពរបស់កម្ពុជា ឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។

និន្នាការទាំងនេះតម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា អនុវត្តកំណែទម្រង់មួយចំនួនដើម្បីធានាបាននូវការប្រកួតប្រជែងដោយយុត្តិធម៌ ការសម្របសម្រួលពាណិជ្ជកម្ម រដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព និងហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង។ ឧទាហរណ៍ ក្រសួងពាណិជ្ជកម្មកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការចុះបញ្ជីអាជីវកម្មភាគច្រើនដោយផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអនឡាញ។ ចាប់តាំងពីឆ្នាំ២០០៩មកអគ្គនាយកដ្ឋានពន្ធដារបានបង្កើនការប្រមូលពន្ធប្រចាំឆ្នាំប្រមាណ ១៩% ជាមធ្យម។

កំណែទម្រង់ទាំងនេះ មានការពិបាក ដោយសារតែសេដ្ឋកិច្ចកម្ពុជា ត្រូវបានគ្របដណ្តប់ដោយសហគ្រាសខ្នាតតូច (បុគ្គលិកតិចជាង ១០នាក់) ដែលក្នុងឆ្នាំ២០១៤ មានប្រមាណ ៩៧.២% នៃគ្រឹះស្ថានធុរកិច្ចទាំងអស់ ហើយមានតែ ១.២% ប៉ុណ្ណោះដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម (ការអង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជា ឆ្នាំ២០១៤)។ លើសពីនេះទៀត ផ្នែកដ៏សំខាន់មួយនៃសេដ្ឋកិច្ច គឺសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយអ្នកធ្វើការជាច្រើន គឺជាអ្នកដែលធ្វើការងារឱ្យខ្លួនឯង ឬជាអ្នកធ្វើការដោយគ្មានកិច្ចសន្យា ដូចជា ការងារបម្រើតាមផ្ទះ ការងារនៅហាងតូចតាច ឬលក់ដូរនៅតាមផ្លូវ។ វាច្បាស់ណាស់ថា គម្លាតរវាងទិសដៅទីផ្សារដែលបានដាក់ចេញនៅកម្ពុជា និងតថភាពនៃការធ្វើអាជីវកម្មនៅតែមាន។

ដូច្នេះ វាប្រាកដណាស់ថា ស្របនឹងសាកលភាវូបនីយកម្មដែលកំពុងបន្ត និងសមាហរណកម្មនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្រុមហ៊ុននៅកម្ពុជាត្រូវធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម និងអនុវត្តសុចរិតភាពធុរកិច្ចក្នុងក្រុមហ៊ុនរបស់ខ្លួន ដើម្បីសហការ និងប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយក្រុមហ៊ុនបរទេស ក្នុងន័យគោរពគោលការណ៍សុចរិតភាពធុរកិច្ច ដើម្បីទាក់ទាញការវិនិយោគ និងកសាងជំនឿចិត្តនៅក្នុងភ្នែករបស់ម្ចាស់ហ៊ុនរបស់ខ្លួន។

ការស្រាវជ្រាវអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ បានរកឃើញថាក្រុមហ៊ុនពហុជាតិ និងរួមទុនភាគច្រើនបានបង្កើតយុទ្ធសាស្រ្តច្បាស់លាស់ក្នុងការប្រឆាំងនឹងអំពើពុករលួយ ប៉ុន្តែមានក្រុមហ៊ុន

របាយការណ៍ស្តីពី "ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ" គឺជាការវាយតម្លៃជាមូលដ្ឋាន ដែលធ្វើការវិភាគទៅលើកិច្ចខិតខំប្រឹងប្រែង របស់វិស័យឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិលក្នុងការពង្រឹងសុចរិតភាពធុរកិច្ច ជាពិសេស គណនេយ្យភាព តម្លាភាព និងសុចរិតភាពនៅពេលបំពេញធុរកិច្ច។ របាយការណ៍នេះ ផ្តល់ការយល់ដឹងបន្ថែមអំពី កត្តា និងសកម្មភាពការងារដែលអាចជួយបង្កើនសុចរិភាពធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលក្នុងការលុបបំបាត់អំពើពុករលួយ។

ក្នុងស្រុកតិចតួចណាស់ ដែលមានគោលនយោបាយគ្រប់គ្រងសុចរិតភាព។ ក្រុមហ៊ុនកម្ពុជាភាគច្រើន មិនមានទម្លាប់បើកចំហកម្មវិធីប្រឆាំងអំពើពុករលួយ កិច្ចប្រតិបត្តិការ ឬរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនទេ ហើយមូលហេតុចម្បង គឺដោយសារតែការបញ្ចេញព័ត៌មានទាំងនេះ មិនត្រូវបានតម្រូវដោយច្បាប់។ ជាទូទៅ ក្រុមហ៊ុនក្នុងស្រុក និងជាពិសេសសហគ្រាសធុនតូច និងមធ្យម ខ្វះខាតវប្បធម៌សាជីវកម្ម និងមើលមិនឃើញពីអត្ថប្រយោជន៍ នៃការអនុវត្តក្រមសីលធម៌យន្តការរាយការណ៍ពីខាងក្នុង និងខាងក្រៅចំពោះករណីអំពើពុករលួយ និងការបើកចំហជាសាធារណៈនូវព័ត៌មានសាជីវកម្ម។ យើងគួរតែគូសបញ្ជាក់ថា ការទទួលយកការអនុវត្តបែបនេះ សម្រាប់ក្រុមហ៊ុនក្នុងស្រុកតូចៗ អាចត្រូវការការចំណាយមួយចំនួន។ មានតែសហគ្រាសដែលចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា (CSX) ប៉ុណ្ណោះ ដែលមានកាតព្វកិច្ចផ្លូវច្បាប់។ លើសពីនេះ មានតែក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិច្រើនជាង៧៥០,០០០ដុល្លារ ទ្រព្យសកម្ម ៥០០,០០០ដុល្លារ និងបុគ្គលិក ១០០នាក់ប៉ុណ្ណោះ ដែលតម្រូវឱ្យដាក់ជូននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ទៅឱ្យសវនករឯករាជ្យ ដែលបានទទួលស្គាល់ដោយ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (KICPAA)។

មធ្យោបាយដ៏សំខាន់មួយសម្រាប់ក្រុមហ៊ុនឯកជន ដើម្បីចូលរួមក្នុងគំនិតផ្តួចផ្តើមពហុភាគី ទៅលើការប្រឆាំងអំពើពុករលួយ គឺតាមរយៈសមាគមធុរកិច្ច និងសភាពាណិជ្ជកម្ម។ អង្គភាពទាំងនេះផ្តល់សេវាកម្មជាច្រើន (ដូចជាការប្រឹក្សាយោបល់ផ្នែកច្បាប់ការបង្កើតបណ្តាញ ការផ្តល់ព័ត៌មានបច្ចុប្បន្នភាព។ល។) ដល់សមាជិករបស់ពួកគេ ហើយក៏បានបង្កើតកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាក្រសួងសំខាន់ៗ ក៏ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ។ ទោះយ៉ាងណាក៏ដោយ គេបានរាយការណ៍ថា ក្រុមហ៊ុនឯកជនទាំងនេះកំពុងបាត់បង់បណ្តាញទំនាក់ទំនងដ៏មានប្រសិទ្ធភាពជាមួយស្ថាប័នសាធារណៈ។

ក្រុមហ៊ុនពហុជាតិធំៗ បានចូលរួមជាផ្លូវការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដោយចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoU)។ ខ្លឹមសារនៃអនុស្សរណៈនៃការយោគយល់គ្នានេះ មិនអាចរកបានជាសាធារណៈនោះទេ ហើយលទ្ធផល និងអត្ថប្រយោជន៍ក្នុងការចូលរួមជាមួយអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ក្រុមហ៊ុននីមួយៗ ជាពិសេសសហគ្រាសធុនតូច និងមធ្យម ក៏មានភាពមិនច្បាស់លាស់ដែរ។ ភាគច្រើនក្រុមហ៊ុនមិនមានតម្លាភាពក្នុងការបញ្ចេញព័ត៌មានអំពីកម្មវិធីប្រឆាំងអំពើពុករលួយ ឬព័ត៌មានសាជីវកម្មរបស់ក្រុមហ៊ុនខ្លួនឡើយ។ ផ្អែកលើការស្រាវជ្រាវអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ វាមានភាពខុសគ្នា រវាងព័ត៌មានដែលមាននៅលើគេហទំព័ររបស់ក្រុមហ៊ុនបរទេស និងគេហទំព័ររបស់ក្រុមហ៊ុនក្នុងស្រុក។ ក្រុមហ៊ុនក្នុងស្រុក មិនមាននិន្នាការបើកចំហគោលនយោបាយប្រឆាំងអំពើពុករលួយ និងព័ត៌មានសាជីវកម្មរបស់ពួកគេ ដោយសារ កង្វះកាតព្វកិច្ចផ្លូវច្បាប់និងវប្បធម៌អភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនមានកម្រិតទាប។

ជារួម ក្រុមហ៊ុនជាច្រើន បង្ហាញពីឆន្ទៈក្នុងការអនុម័តកម្មវិធីប្រឆាំងអំពើពុករលួយ និងចង់អនុលោមទៅតាមច្បាប់បច្ចុប្បន្ន។ ដើម្បីអភិវឌ្ឍអភិបាលកិច្ចសាជីវកម្ម ពិសេសនៅក្នុងក្រុមហ៊ុនក្នុងស្រុក គឺចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការកាន់តែច្រើនឡើង និងការបណ្តុះបណ្តាលជាមួយភាគីពាក់ព័ន្ធ ហើយក៏តម្រូវឱ្យមានគំនិតផ្តួចផ្តើមច្បាប់បន្ថែមទៀត ទាក់ទងនឹងការលើកកម្ពស់អភិបាលកិច្ចសាជីវកម្ម និងការអនុម័តគោលនយោបាយប្រឆាំងអំពើពុករលួយ។ យន្តការរាយការណ៍បន្ថែមគួរតែត្រូវបានណែនាំ ហើយព័ត៌មានបន្ថែមគួរតែត្រូវបានបង្ហាញនៅលើគេហទំព័ររបស់ក្រុមហ៊ុន។ វាមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយទំហំនៃវិស័យធុរកិច្ចក្រៅផ្លូវការ ដោយផ្តល់ការលើកទឹកចិត្តដល់សហគ្រាសនានា ឱ្យចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ហើយឱ្យសមាគមធុរកិច្ចជួយលើកទឹកចិត្ត ឱ្យបានខ្លាំងក្លានិងសម្រួលដល់ការចុះបញ្ជីនេះ។ វិធានការទាំងនេះនឹងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនៅកម្ពុជា និងការប្រកួតប្រជែងរបស់សហគ្រាសក្នុងស្រុក។

## អនុសាសន៍សំខាន់ៗសម្រាប់វិស័យធុរកិច្ច រួមមាន៖

- សភាពាណិជ្ជកម្ម និងសមាគមធុរកិច្ច គួរតែបើកចំហព័ត៌មាន អំពីអត្ថប្រយោជន៍នៃការចូលរួមយ៉ាងជិតស្និទ្ធជាមួយអង្គភាពប្រឆាំងអំពើពុករលួយដល់សមាជិករបស់ពួកគេ ជាពិសេសគឺសារៈសំខាន់នៃការការពារបុគ្គលដែលរាយការណ៍ទៅអង្គភាពប្រឆាំងអំពើពុករលួយ។
- សមាគមធុរកិច្ច និងសភាពាណិជ្ជកម្ម គួរតែបន្តរៀបចំវគ្គបណ្តុះបណ្តាលអំពីសុចរិតភាពធុរកិច្ច និងការអនុវត្តរបស់សាជីវកម្ម (ដូចជា ក្រមសីលធម៌ ក្រមវិជ្ជាជីវៈ យន្តការរាយការណ៍ប្រឆាំងនឹងអំពើពុករលួយ គោលនយោបាយប្រឆាំងអំពើពុករលួយ) រួមទាំង ការធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីបង្កើត និងបណ្តុះបណ្តាលអំពីការអនុវត្តល្អៗ។
- សមាគមធុរកិច្ចគួរតែកំណត់បទដ្ឋានសម្រាប់សុចរិតភាពធុរកិច្ច នៅក្នុងឧស្សាហកម្មនីមួយៗ ហើយទទួលស្គាល់ព្រមទាំងផ្តល់រង្វាន់ដល់ក្រុមហ៊ុនដែលសម្រេចគោលចំណុចទាំងនោះបានជោគជ័យ។
- ក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិ គួរបង្កើតយន្តការ ដែលត្រូវបានការពារ និងមានលក្ខណៈអនាមិក ដើម្បីលើកទឹកចិត្តដល់បុគ្គលិកគ្រប់កម្រិត ឱ្យរាយការណ៍ពីករណីអំពើពុករលួយ ឬការធ្វើខុសឆ្គងផ្សេងៗទៀត។
- ក្រុមហ៊ុន គួរតែធានានូវការអនុលោមតាមការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ។ សមាគមធុរកិច្ច គួរតែលើកទឹកចិត្តដល់ដំណើរការនិងជួយតាមដែលអាចធ្វើទៅបាន។
- ក្រុមហ៊ុន គួរតែបើកចំហពីគោលនយោបាយ និងសកម្មភាពប្រឆាំងអំពើពុករលួយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងនៅលើគេហទំព័ររបស់ខ្លួន។

- សមាគមធុរកិច្ច គួរលើកទឹកចិត្តក្រុមហ៊ុនឱ្យយល់ដឹងពីតម្លៃនៃការអនុវត្តគណនេយ្យភាពស្អាតស្អំ និងអត្ថប្រយោជន៍បន្ថែមរបស់សេវាកម្មគណនេយ្យវិជ្ជាជីវៈ។
- ក្រុមហ៊ុននានា គួរតែមានតម្រូវការប្រឆាំងអំពើពុករលួយឱ្យបានហ្មត់ចត់ពីដៃគូ និងអ្នកផ្គត់ផ្គង់របស់ខ្លួនព្រមទាំងចងក្រងទិន្នន័យនៃក្រុមហ៊ុនដែលស្អាតស្អំ។
- ក្រុមហ៊ុនឯកជន គួរតែផ្តល់ឱ្យនូវយន្តការច្រើនថែមទៀតដើម្បីរាយការណ៍ពីករណីអំពើពុករលួយ។ ការរាយការណ៍ទៅតែអង្គភាពប្រឆាំងអំពើពុករលួយមួយកន្លែង គឺមិនគ្រប់គ្រាន់ទេ។
- សភាពាណិជ្ជកម្ម គួរលើកកម្ពស់ និងផ្តល់យោបល់ដល់ក្រសួងនានា ឱ្យធ្វើសេចក្តីព្រាងច្បាប់ និង ប្រកាសឱ្យប្រើប្រាស់ច្បាប់ពាក់ព័ន្ធ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នករាយការណ៍ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី ព្រមទាំងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង និងធ្វើបច្ចុប្បន្នភាពច្បាប់មានស្រាប់ ដែលមានលក្ខណៈហួសសម័យឬខុសពីទិសដៅប្រឆាំងអំពើពុករលួយ។ ការណ៍នេះគួរតែប្រព្រឹត្តទៅដោយមានការពិគ្រោះយោបល់ ជាមួយវិស័យឯកជន និងសង្គមស៊ីវិល។


អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ៣ ផ្លូវលេខ ៣៩០
សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

( +855 ) 23 214 430

*Website: www.ticambodia.org*
*Global website: www.transparency.org*